# ការសំភាសន៍របស់អ៊ុំប្រុស ខឹម សារិន

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ ខឹម សារិន

<u>ការសង្ខេបប្រវត្តិរបស់ អ៊ុំប្រុស ខឹម សារិន</u>

អ៊ុំប្រុស ខឹម សារិន មានអាយុ នៅក្នុងឆ្នាំ2018 អ៊ុំប្រុស ខឹម សារិន មានភេទប្រុស

អ៊ុំប្រុស ខឹម សារិន មានទីលំនៅបច្ចុប្បន្ននៅភូមិ។

កៈ ចឹងជាដំបូងខ្ញុំអរគុណអ៊ុំដែរបានអោយខ្ញុំពិភាក្សាជាមួយអ៊ុំដែរទាក់ទងពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU
ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយនឹងប្រវត្តិរបស់ដូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍អ៊ុំ
ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu
ចឹងសំរាប់អ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ ប្រវត្តិកាលខ្ញុំពីក្មេងនឹងវាកាលពីអ៊ីសារ៉ាក់មុនហាស

កៈ បាទប៉ុន្តែអ៊ុំយល់ព្រមដើម្បីអោយយើងដាក់ប្រវត្តិរបស់អ៊ុំ ដើម្បីទុកអោយកូនចៅរបស់អ៊ុំបានស្ដាប់ទេអ៊ុំ?

ខៈ ចុះយើងមានទូរស័ព្ទណា

កៈ ប៉ុន្តែអត់អីទេណាអ៊ុំបើយើងចង់ដាក់ប្រវត្តិរបស់អ៊ុំ?

ខៈ បើយើងមានទូរស័ព្ទយើងថតជាប់បាត់ទៅហើយនឹង

កៈ បាទអ៊ុំបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍អ៊ុំគឺនៅថ្ងៃទី26ខែ3 ឆ្នាំ2018 គឺសំភាសន៍នៅភូមិត្នោតជ្រុំណាអ៊ុំ?

ខ៖ នឹងហើយនៅភូមិត្នោតជ្រុំ3នឹង

ក៖ នៅភូមិត្នោតជ្រុំ3 ចុះសង្កាត់ផ្សារដើមថ្កូវ?

ខ៖ នៅសង្កាត់ផ្សារដើមថ្កូវនឹង

ក៖ ខ័ណ្ឌចំការមកហោមិនមែនទេអ៊ុំ?

ខ៖ ខ័ណ្ឌមានជ័យ

ក៖ សង្កាត់បឹងទំពុនហីអ៊ុំ?

ខ៖ បាទសង្កាត់បឹងទំពុននឹងហើយ

ក៖ នៅខ័ណ្ឌមានជ័យ នៅរាជធានីភ្នំពេញនឹង?

ខ៖ នឹងហើយចឹង

ក៖ ចឹងសំរាប់អ៊ុំមានឈ្មោះពេញនឹងមានឈ្មោះអីគេដែរទៅអ៊ុំ?

ខ៖ ឈ្មោះរបស់ខ្ញុំហោសឈ្មោះខឹម សារិន

ក៖ ចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖ ហៅក្រៅមានដែរប៉ុន្តែនេះគេអត់ប្រើផងនឹង

ក៖ ប៉ុន្តែគេហៅឈ្មោះអីគេដែរទៅអ៊ុំ?

ខ៖ មានឈ្មោះសា រុន

ក៖ ចឹងមានឈ្មោះថា សារុន ណអ៊ុំ?

ខ៖ ក្រោយមកនឹងបានខ្ញុំដាក់ឈ្មោះសា រិនវិញនឹង

ក៖ ចុះកាលពីក្មេងនឹងមាននរណាហៅឈ្មោះអ៊ុំអីផ្សេងទេអ៊ុំ?

ខ៖ ឥឡូវនឹងហោស?

ក៖ បាទកាលពីក្មេងនឹងមាននរណាហៅឈ្មោះអ៊ុំអីផ្សេងដែរទេ?

ខ៖ អត់ទេៗនឹងបាស

ក៖ អត់ទេណាអ៊ុំ?

ខ៖ នឹងហើយអត់មានទេ

ក៖ ចុះសព្វថ្ងៃនឹងអ៊ុំមានអាយុប៉ុន្មានដែរទៅអ៊ុំ?

ខ៖ ខ្ញុំអាយុ70ឆ្នាំហើយនឹង

ក៖ ចឹងមានន័យថាអ៊ុំអាយុ70ឆ្នាំហើយណាអ៊ុំ?

ខ៖ នឹងហើយ

ក៖ ចុះអ៊ុំមានដឹងថាអ៊ុំកើតនៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខ៖ មើលនៅក្នុងអត្តសញ្ញាណប័ននឹងវាអាយុ70ឆ្នាំហើយនឹង

ក៖ ឈប់អ៊ុំចាំមួយភ្លេតអ៊ុំ?

ខ៖ ខ្ញុំអាយុ70ឆ្នាំហើយនឹង

ក៖ ចឹងអ៊ុំកើតនៅឆ្នាំ1948ហាសអ៊ុំ?

ខ៖ នឹងហើយចឹង

ក៖ ចុះដូចជាថ្ងៃខែអ៊ុំមានចងចាំទេអ៊ុំ?

ខ៖ កាលណុងខែកាលណុងជំនាន់លិចទឹកហាស

ក៖ អ៎ូ!!បាទអ៊ុំបាទ?

ខ៖ ណុងហើយកាលណុងលិចទឹកអស់លើងហើយនឹង
ទាអីនឹងហែលហែងពេញទឹកនឹងហាស

ក៖ បាទអ៊ុំបាទចុះអ៊ុំ?

ខ៖ ហើយអាផ្ទះលើអត់អីទេប៉ុន្តែអាផ្ទះក្រោមនឹងលិចអស់នឹងហាស
ផ្ទះក្បៀនបីខ្ទងនឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ នឹងហើយនៅស្រុកនឹងហាស

ក៖ ប៉ុន្តែអ៊ុំឆ្នាំច័ន្ទគតិអ៊ុំមានឆ្នាំអីគេដែរអ៊ុំ លក្ខណៈឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខ៖ មើលខ្ញុំអាយុ70ឆ្នាំមិនចេះរាប់ទៀតនឹងហាស

ក៖ អូ៎!!អ៊ុំអត់ចេះរាប់ទេហោសអ៊ុំ?

ខ៖ នឹងហើយអត់ចេះទេ

ក៖ ចុះអ៊ុំកើតនៅណាដែរអ៊ុំ?

ខ៖ ខ្ញុំបានកើតនៅព្រៃវែង

ក៖ ចុះនៅភូមិអី ឃុំអីគេដែរអ៊ុំ?

ខ៖ ភូមិមឿងពាន់ ឃុំត្រពាំងស្រែ ខេត្តព្រៃវែងនឹង

ក៖ ចុះនៅស្រុកអីគេដែរអ៊ុំ?

ខ៖ នៅស្រុកមេសាង

ក៖ នៅស្រុកមេសាងហោសអ៊ុំ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ ខ្ញុំមានបងប្អូនចំនួន6នាក់អូ៎!!មាន7នាក់

ក៖ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ អូ៎!!សួរខ្ញុំទេហោស?

ក៖ បាទអ៊ុំបាទ?

ខ៖ ខ្ញុំមានបងប្អូនចំនួន7នាក់នឹង

ក៖ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំជាកូនទៅ5

ក៖ ចុះមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរទៅអ៊ុំ?

ខ៖ មានស្រី3នាក់នឹង ប្រុស4នាក់នឹងហើយ

កៈ  មានស្រី3នាក់នឹងប្រុស4នាក់
ចុះបងប្អូនរបស់អ៊ុំសព្វថ្ងៃនឹងគាត់នៅរស់ទាំងអស់គ្នារឺមួយក៏គាត់នៅ មានអ្នកស្លាប់ដែរ?

ខៈ  មានស្លាប់កាលពីពលពតនឹងយកទៅសំលាប់នឹង

កៈ  មានប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ  មួយគ្រួសារគាត់ម្នាក់ទេស្លាប់នឹងហោសប្រុស

កៈ  ក្រៅពីនឹងនៅ6នាក់ណាអ៊ុំ?

ខៈ  នឹងហើយនៅ6នាក់នឹងហាស

កៈ  ចុះអ៊ុំអាចប្រាប់ឈ្មោះបងប្អូនរបស់អ៊ុំបានទេថាពួកគាត់មានឈ្មោះអីគេខ្លះដែរទៅអ៊ុំ?

ខៈ  បងស្រីនឹងមានឈ្មោះផ្លឹង

កៈ  បងស្រីឈ្មោះផ្លឹង ចុះបងទី2វិញអ៊ុំ?

ខៈ  បងទី2នឹងមានឈ្មោះចឹង

កៈ  ចុះបងទី3វិញអ៊ុំ?

ខៈ  បងទី3នឹងមានឈ្មោះឡញ ប្រុស

កៈ  ចុះទី4វិញអ៊ុំ ទី4នឹងអ៊ុំហីអ៊ុំ?

ខៈ  នឹងហើយខ្ញុំនឹង

កៈ  ចុះទី5វិញអ៊ុំ?

ខៈ  ទី5នឹងប្អូនទៀតប្រុសទេ

កៈ  ប៉ុន្តែគាត់មានឈ្មោះអីគេដែរទៅអ៊ុំ?

ខៈ  វាឈ្មោះហេង

កៈ  ចុះប្អូនទី6វិញអ៊ុំ?

ខៈ  ប្អូនទី6នឹងមានឈ្មោះស ស្រីហាស

កៈ ចុះទី7វិញអ៊ុំឈ្មោះអី?

ខៈ ប្អូនទី7នឹងស្លាប់ណុងហើយ

កៈ ប៉ុន្តែគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ វាមានឈ្មោះឡូញ

កៈ អូ៎!!អ្នកដែរស្លាប់នឹងកូនពៅគេហោសអ៊ុំ?

ខៈ អត់ទេបងខ្ញុំតើនឹង

កៈ អូ៎!!បាទអ៊ុំចុះអ៊ុំមានធ្លាប់មានអនុស្សាវរីយ៍អីកាលពីនៅក្មេងៗធ្លាប់លេងអីគេខ្លះជាមួយបងប្អូនរបស់អ៊ុំដែរទេដូចជាលេងបិទពួន លេងឡឹកបាយឡ នឹងលេងអីទេអ៊ុំ?

ខៈ អានឹងពេលណុងយើងទៅឃ្វាលក្របីលេងអីនឹងលេងប៉ែងអីនឹង

កៈ អូ៎!!លេងកូនប៉ែងហោសអ៊ុំ?

ខៈ នឹងហើយលេងអានឹង

កៈ លេងនៅស្រែហោសអ៊ុំ?

ខៈ លេងនៅស្រែចុះយើងនៅស្រែនឹង មើលក្របី មើលគោចឹងទៅណាស់

កៈ បាទអ៊ុំបាទនឹង?

ខៈ ដល់ហើយបបួលគ្នាលេងចឹងទៅណាស់

កៈ ចុះអ៊ុំចូលចិត្តលេងអីគេដែរជាមួយបងប្អូនរបស់អ៊ុំដែរ?

ខៈ ជាមួយបងប្អូនបង្កើតហោស?

កៈ បាទអ៊ុំ ចូលចិត្តលេងអីគេដែរអ៊ុំ?
ខៈ អត់សោះនឹងលេងតែជាមួយអ្នកនៅក្នុងភូមិនឹង

កៈ ចឹងហោសអ៊ុំ?

ខៈ នឹងហើយចឹង

កៈ ចុះអ៊ុំគិតថាបងប្អូនរបស់អ៊ុំនឹងឥឡូវនឹងគាត់នៅណាដែរអ៊ុំ?

ខៈ នៅស្រែនឹងមានពីរនាក់ទៅ បីនាក់នឹងនៅនេះពីរនាក់

កៈ អូ៎!!ប៉ុន្តែពួកគាត់នៅព្រៃវែងនឹងហោសអ៊ុំ?

ខៈ នៅព្រៃវែងនឹងហើយ

កៈ ប៉ុន្តែពួកគាត់នៅព្រៃវែងនឹងពួកគាត់ធ្វើអីគេដែរទៅអ៊ុំ?

ខៈ គាត់ធ្វើស្រែនឹងហាស

កៈ គាត់ធ្វើស្រែដែរណាអ៊ុំណា?

ខៈ ហើយខ្ញុំពីរនាក់បងប្អូននឹងនៅនេះ

កៈ ចុះអ្នកនៅភ្នំពេញនឹងបងរបស់អ៊ុំរឺមួយក៏ប្អូនរបស់អ៊ុំដែរ?

ខៈ ប្អូនរបស់ខ្ញុំទេ

កៈ ប៉ុន្តែគាត់ធ្វើអីគេដែរនៅណុងហាសអ៊ុំ?

ខៈ គាត់រកស៊ីខាងសាងសងផ្ទះនឹងហាស

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ នឹងហើយចឹង

កៈ ចុះឪពុករបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់មានឈ្មោះឡឹង ម្តាយហោស

កៈ ចុះគាត់មានឈ្មោះស្អីគេឡឹងដែរអ៊ុំ?

ខៈ គាត់ឈ្មោះកាំ ឡឹង

កៈ គាត់មានឈ្មោះកាំ ឡឹង ចុះម្តាយគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់មានឈ្មោះឃិន នាង

កៈ ចុះឪពុកដល់ឥឡូវនឹងអ៊ុំមានដឹងថាគាត់អាយុប៉ុន្មានដែរទេ?

ខ៖ ឥឡូវនឹងហោសគាត់ស្លាប់អស់ជាង10ឆ្នាំហើយនឹង វាចូលកៅជាងហើយនឹងហាស

ក៖ ចឹងណអ៊ុំណ ចុះឪពុករបស់អ៊ុំគាត់កើតនៅណាដែរអ៊ុំ?

ខ៖ គាត់នៅព្រៃវែងនឹងដែរនឹង

ក៖ ចុះម្ដាយរបស់អ៊ុំគាត់កើតនៅណាដែរអ៊ុំ?
ខ៖ កាត់នៅភូមិតែមួយនឹងហាស

ក៖ ប៉ុន្តែម្ដាយរបស់អ៊ុំនឹងគាត់ដូចជាប្អូនតាប៉ុន្មានឆ្នាំដែរអ៊ុំ?

ខ៖ គាត់ប្អូនតាឪពុករបស់ខ្ញុំបង្កើតនឹងហោស?

ក៖ បាទអ៊ុំបាទនឹង?

ខ៖ គាត់ប្អូនគ្នាជាង10ឆ្នាំហោស

ក៖ អូ៎!!ចឹងណអ៊ុំណ?

ខ៖ នឹងហើយចឹង

ក៖ ប៉ុន្តែតានឹងយាយគាត់ស្លាប់អស់ហើយមែនទេអ៊ុំ?

ខ៖ គាត់ស្លាប់អស់ហើយនឹងហាស

ក៖ ប៉ុន្តែតានឹងកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖ អើរគាត់ធ្វើស្រែដែរនឹងហាស ហើយគាត់ធ្វើអាត្បាលកិនស្រូវអីនៅផ្ទះនឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទ ចុះគាត់កាចរឺមួយក៏គាត់ស្លូតដែរអ៊ុំ?

ខ៖ គាត់អត់កាចទេគាត់ស្លូតដែរនឹងគាត់នៅទាល់តែជីវិតរបស់គាត់នឹងអស់នឹង

ក៖ បាទចឹងហោសអូបាទអ៊ុំ?

ខ៖ គាត់មានដែរឈឺអីផងនឹងហាស

ក៖ យាយកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖ គាត់នៅផ្ទះដាំបាយដាំអីនឹងហាស

កៈ អ៊ូ!!ចុះយាយគាត់កាចរឺមួយក៏គាត់ស្លូតដែរអ៊ុំ?

ខៈ គាត់ស្លូតដែរតើ ម្ដាយរបស់ខ្ញុំនឹងគាត់ស្លូតទេ

កៈ ចុះអ៊ុំធ្លាប់មានអនុស្សាវរីយ៍អីកាលពីអ៊ុំនៅជាមួយឪពុកម្ដាយរបស់អ៊ុំទេ មានសាច់រឿងអីដែរអ៊ុំគិតថាអ៊ុំចងចាំអត់ភ្លេចហាសទៅស្រែរឺមួយក៏ធ្វើអីមួយចឹងហាសអ៊ុំ?

ខៈ អត់មានសោះនឹងហាស

កៈ ចឹងអត់មានធ្វើអីទេណាអ៊ុំ?

ខៈ ណុងហើយនឹង

កៈ លក្ខណះជាញុំាបាយជុំគ្នាដែរធ្វើអោយអ៊ុំចងចាំអត់ភ្លេចហាស?

ខៈ ណុងហើយមានតែប៉ុណ្ណឹង

កៈ ចឹងហោសអ៊ុំ ចុះអ៊ុំគិតថាឪពុករបស់អ៊ុំគាត់មានធ្លាប់ប្រាប់ពីប្រវត្តិគាត់កាលពីគាត់នៅក្មេងទៅអ៊ុំដែរទេ?

ខៈ កាលពីគាត់នៅក្មេងហោស?

កៈ បាទអ៊ុំគាត់មានធ្លាប់ប្រាប់ទេ?

ខៈ កាត់នៅរកស៊ីចឹងគាត់ធ្វើស្រែធ្វើអីចឹង

កៈ អ៊ូ!!ចឹងហោសអ៊ុំបាទចឹង?

ខៈ មានរកស៊ីអីទេគ្មានលក់ដូរអីផងនឹង

កៈ ចុះម្ដាយរបស់អ៊ុំវិញគាត់មានដែរប្រាប់ពីប្រវត្តិរបស់គាត់កាលពីគាត់នឹងនៅក្មេងទៅអ៊ុំដែរទេ?

ខៈ គាត់នឹងធ្វើស្រែដែរនឹងនៅភូមិនឹងគាត់មានធ្វើអីទេ

កៈ បាទអ៊ុំចុះយាយតាខាងឪពុករបស់អ៊ុំនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ យាយតាខាងឪពុករបស់ខ្ញុំនឹងហោស?

កៈ បាទអ៊ុំបាទ?

ខៈ គាត់មានឈ្មោះតាកាំនឹងហើយកាំនឹងហើយ

កៈ អត់ទេយាយតាខាងឪពុកមួយទៀតហាស ឪពុករបស់អ៊ុំនឹងមានឈ្មោះកាំ

ខៈ ចុះឈ្មោះជីតាឪពុករបស់គាត់នឹងហាសដាក់ត្រកូលនឹងមិនឈ្មោះកាំ

កៈ បាទអ៊ុំបាទចុះយាយវិញ?

ខៈ យាយនឹងគាត់មានឈ្មោះត្រាង

កៈ គាត់មានឈ្មោះត្រាង ចុះយាយតាខាងឪពុកនឹងគាត់កើតនៅណាអ៊ុំមានដឹងទេ?

ខៈ ពួកគាត់កើតនៅព្រៃវែងនឹងដែរនឹង

កៈ ចុះយាយតាខាងម្ដាយវិញអ៊ុំ?

ខៈ គាត់កើតព្រៃវែងនឹងដែរនឹង

កៈ ប៉ុន្តែពួកគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ តានឹងគាត់មានឈ្មោះខិន

កៈ ចុះយាយវិញអ៊ុំមានឈ្មោះអី?

ខៈ យាយមានឈ្មោះអុន

កៈ អូ៎!!បាទចុះអ៊ុំមករស់នៅទីក្រុងភ្នំពេញនឹងយូរនៅអ៊ុំ?

ខៈ នឹងហើយ ខ្ញុំមកនៅបាន20ឆ្នាំជាងហើយនឹង

កៈ ចុះអ៊ុំមានបងប្អូនកូនចៅណាដែររស់នៅក្រៅប្រទេសទេអ៊ុំ?

ខៈ មានមានតែខាងគ្រួសាររបស់ខ្ញុំនឹងមានគាត់នៅអាមេរិចនឹង

កៈ គាត់នៅអាមេរិចហោសអ៊ុំ?

ខៈ នឹងហើយនៅអាមេរិច

កៈ ចុះគាត់នៅរដ្ឋណាដែរអ៊ុំមានបានដឹងអត់អ៊ុំ?

ខ៖
គាត់នៅជាយក្រុងដែរនឹងមិនដឹងថាជារដ្ឋអីទេបងថ្លៃគាត់ទើបតែទៅហើយគាត់មកវិញយប់នឹងហាស

ក៖ គាត់មកវិញយប់នឹងហោសអុំ?

ខ៖ នឹងហើយ

ក៖ អូ!!ឡូយហាសណាអុំ?

ខ៖ នឹងហើយគាត់ទៅជិតមួយខែហោស
យប់នឹងគាត់ឡើងយន្តហោះហើយយើងដេកចឹងគេភ្លឺ

ក៖ បាទៗត្រូវហើយអុំ?

ខ៖ វាមិនចឹងមែនអត់ ហើយមួយយប់ពីរថ្ងៃបានដល់នឹង

ក៖ អូ!!បាទអុំ ចុះគាត់ធ្វើអីគេដែរនៅណុងហាសអុំ?

ខ៖ អើរគាត់ចាស់ហើយគាត់នៅមើលចៅមើលអីនឹងហាស

ក៖ កូនគាត់ធ្វើការងារនៅណុងហោស?

ខ៖ គាត់ទើបតែទៅដែរនឹងគេធ្វើការនៅណុងហាស

ក៖ អូ!!បាទអុំបាទ?

ខ៖ គេមានសញ្ជាតិគេនៅណុងហើយនឹង

ក៖ ចុះភរិយារបស់អុំនឹងគាត់មានឈ្មោះអីគេដែរអុំ?

ខ៖ គាត់មានឈ្មោះឃាំង

ក៖ ចុះគាត់មានឈ្មោះស្អីគេឃាំងដែរទៅអុំ?

ខ៖ គាត់មានឈ្មោះតាំង ឃាំង

ក៖ ចុះដូចជាអុំមានចងចាំថាអុំរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរទេអុំ?

ខ៖ អូ!!តាំងពីឆ្នាំ1979ហោស

កៈ អូ៎!!នៅឆ្នាំ1979ហោសអ៊ុំ?

ខៈ ប៉ុន្តែមិនដឹងថានៅថ្ងៃណាខែណាឆ្នាំណាដែរភ្លេចអស់ហើយនឹង

កៈ ប៉ុន្តែដឹងតែអ៊ុំរៀបនឹងនៅជំនាន់ឆ្នាំ1979នឹង?

ខៈ នៅឆ្នាំ1979នឹងហាស

កៈ
ចុះនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍នឹងដូចជាអ៊ុំជាអ្នករៀបចំដោយចិត្តឯងរឺមួយក៏ឪពុកម្តាយ ពួកគាត់ជាអ្នករៀបអោយដែរអ៊ុំ?

ខៈ ឪពុកម្តាយនឹងរៀបអោយតើ!!នឹង

កៈ ប៉ុន្តែអ៊ុំចូលស្តីដណ្តឹងអ៊ុំស្រីនឹងដូចជាមានជាជំនូនជូនគាត់ដែរទេ?

ខៈ កាលណុងមានចុះកាលណុងលុយវាថ្លៃហាស

កៈ ប៉ុន្តែកាលណុងជូនប៉ុន្មានដែរអ៊ុំ?

ខៈ មិនដឹងថាប៉ារបស់ខ្ញុំនឹងគាត់ជូនប៉ុន្មានដែរនឹងហាស

កៈ អូ៎!!អ៊ុំអត់សួរដឹងផងហោសអ៊ុំ?

ខៈ នឹងហើយនឹង

កៈ ប៉ុន្តែអ៊ុំស្គាល់អ៊ុំស្រីពីមុនអត់?

ខៈ កាលពីដើមមកនឹងហោស

កៈ ពីមុនអ៊ុំចូលស្តីដណ្តឹងគាត់ហាសអ៊ុំមានស្គាល់គាត់ពីមុនអត់?

ខៈ នឹងតាខ្សែរយៈអ៊ុំរបស់ខ្ញុំទេរយៈគាត់នឹងហាស

កៈ អូ៎!!បាទអ៊ុំបាទចឹង?

ខៈ នឹងហើយអត់ដែរជួបគ្នាសោះនឹង

កៈ អូ៎!!បាទចឹងមានន័យថាណែនាំពីឪពុកម្តាយទាំងសងខាងហោសអ៊ុំ?

ខ៖ នឹងហើយចឹង

ក៖ ចុះអ៊ុំមានធ្លាប់ដែរបានរៀនទេអ៊ុំ?

ខ៖ ខ្ញុំរៀនបានត្រឹមតែថ្នាក់ទី6នឹងខ្ញុំបានឈប់រៀនទៅ

ក៖ ប៉ុន្តែកាលពីអ៊ុំរៀននឹងអ៊ុំរៀននៅណាដែរអ៊ុំ?

ខ៖ ខ្ញុំរៀននៅស្រុកស្រែនឹងនៅវត្ត

ក៖ អ៊ុំរៀននៅវត្តហោសអ៊ុំ ប៉ុន្តែវត្តនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ វត្តនឹងមានឈ្មោះថាអង្គរឃ្លោកថ្មី

ក៖ អូ៎!!បាទអ៊ុំចុះនៅពេលដែរអ៊ុំរៀននឹងគិតថាអ៊ុំមានធ្លាប់មានមិត្តភក្តិរឺមួយក៏ស្និទ្ធស្នាលធំធាត់មកជាមួយគ្នាដែរទេ?

ខ៖ ពីមុនមកនឹងហោសមានដែរប៉ុន្តែគេធ្វើការងារធំនៅស្រុកនឹងដែរតើ!!

ក៖ អូ៎!!បាទអ៊ុំ ចុះពួកគាត់មានឈ្មោះអីគេដែរអ៊ុំមានចងចាំឈ្មោះដែរអ៊ុំគិតថាអ៊ុំចងចាំបានទេ?

ខ៖ ដូចថាមិត្តភក្តិរបស់យើងនឹងដូចថាឈ្មោះឆេងនឹងអាណុង

ក៖ អូ៎!!មានតែម្នាក់ណុងដែរតើហីអ៊ុំ?

ខ៖ នឹងហើយកូនមរឃុំហាស

ក៖ បាទអ៊ុំបាទនឹងហើយ?

ខ៖ ពីដើមនឹងពីដើមនឹងមេឃុំនឹងហើយ

ក៖ ចុះអ៊ុំគិតថាអ៊ុំធ្លាប់មានប្រវត្តិអីជាមួយអ៊ុំឆេងនឹងដែរទេអ៊ុំ កាលពីនៅក្មេងៗហាស?

ខ៖ ប្រវត្តិមានតែការរៀនសូត្រជាមួយគ្នានឹងហាសគគ្មានបានធ្វើអីទេ

ក៖ ធ្លាប់ដើរលេងទៅស្រែអីជាមួយគ្នាចឹងហោសអ៊ុំ?

ខ៖ អត់ទេអត់ដែរដើរផងនឹងដូចថាចូលសាលារៀនជាមួយគ្នាចឹងហាស

កៈ បាទអ៊ុំបាទចឹង?

ខៈ ណុងហើយចឹង

កៈ ប៉ុន្តែអ៊ុំធ្លាប់ដូចជាអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេអ៊ុំ?

ខៈ អើរៀនបារាំងដែរប៉ុន្តែឥឡូវនឹងបានភ្លេចអស់ហើយនឹងហាស

កៈ ប៉ុន្តែកាលពីមុននឹងអ៊ុំមានចេះភាសាបារាំងណាអ៊ុំ?

ខៈ ពីមុននឹងខ្ញុំចេះដែរតើ ប៉ុន្តែឥឡូវនឹងខ្ញុំភ្លេចអស់ហើយនឹង

កៈ អូ៎!!បាទអ៊ុំ ចុះភាសាថៃ វៀតណាមអីអ៊ុំអត់មានចេះទេ?

ខៈ វៀតណាមនឹងអត់ចេះទេ ថៃនឹងក៏អត់ចេះដែរនឹងហាស

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ ថៃនឹងមានតែកូននៅថៃមួយនឹងហាស

កៈ អូ៎!!ចឹងមានតែអ៊ុំមានកូននៅថៃដែរហោសអ៊ុំ?

ខៈ មាននៅថៃនឹងហាសនៅរៀបចំអោយវាយកប្រពន្ធថៃ

កៈ អូ៎!!បាទអ៊ុំបាទចុះ?

ខៈ ទើបតែការអោយវាប៉ុន្មានដែរមុននឹងហាស

កៈ ចុះអ៊ុំគិតថា តើអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះដែរជុំនៅក្នុងជីវិតរបស់អ៊ុំហាស?

ខៈ ខ្ញុំកាលណុងខ្ញុំជួសជុលម៉ូតូនៅភ្នំពេញនឹងហាស

កៈ អូ៎!!អ៊ុំជាអ្នកជួសជុលម៉ូតូហោសអ៊ុំ?

ខៈ កាលពីមុននឹងខ្ញុំនៅផ្សារកណ្តាលហោស

កៈ ចឹងមានន័យថាអ៊ុំធ្លាប់ធ្វើម៉ូតូហើយចឹង?

ខៈ បាទ៎!!ជួសជុលម៉ូតូជួសជុលកងអីនឹងហាស

កៈ អូ៎!!ប៉ុន្តែអ៊ុំមានធ្វើអីផ្សេងពីនឹងទៀតអត់អ៊ុំ?

ខ៖ អើរមុនណុងបានធ្វើការងារអោយជប៉ុនបាន2ឆ្នាំដែរនឹង

ក៖ អូ៎!!បាទអ៊ុំបាទចឹង?

ខ៖ ចែកអំណោយចែកអីចឹងទៅ

ក៖ អូ៎!!ចឹងអ៊ុំចេះភាសាជប៉ុនហោសអ៊ុំ?

ខ៖ អត់ចេះទេប៉ុន្តែមានមេគេចេះបកប្រែហាស

ក៖ អូ៎!!ចឹងទេហោសអ៊ុំបទអ៊ុំបាទ?

ខ៖
នឹងហើយវាចឹងឯងហើយយើងចេះតែធ្វើទៅហើយជួសជុលទៅយកទៅចែកៗៗចឹងទៅណាស់

ក៖ បាទអ៊ុំ ចុះអ៊ុំមានធ្លាប់ធ្វើស្រែចំការទេអ៊ុំ?

ខ៖ ធ្វើតើ!!ខ្ញុំធ្វើស្រែដែរតើនឹង

ក៖ ចុះអ៊ុំមានធ្វើអីគេខ្លះដែរនៅស្រែនឹងហាសអ៊ុំ?

ខ៖ ធ្វើស្រែនឹងភ្ជួរស្រែអីចឹងទៅនឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទចឹង?

ខ៖ ហើយនឹងយកស្រូវមកផ្ទះចឹងទៅ

ក៖ ចុះអ៊ុំគិតថាអ៊ុំធ្លាប់បើកអាជីវកម្មមុខរបរលក់ដូរអីទេអ៊ុំ?

ខ៖ អត់ទេអត់មានផងនឹង

ក៖ ចុះអ៊ុំគិតថាអ៊ុំមានធ្លាប់ចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូក ចិញ្ចឹមគោ ចិញ្ចឹមក្របីអីដែរទេអ៊ុំ?

ខ៖ មានអានឹងមានដែរអូ ចិញ្ចឹមគោ ក្របីនឹងមាន

ក៖ ប៉ុន្តែអ៊ុំចិញ្ចឹមអីគេខ្លះដែរទៅអ៊ុំ?

ខ៖ ចិញ្ចឹមគោ ចិញ្ចឹមមាន់ ចិញ្ចឹមក្របី ចិញ្ចឹមទា ចិញ្ចឹមជ្រូក ចិញ្ចឹមអីនឹងហាស

កៈ ប៉ុន្តែអ៊ុំមានចិញ្ចឹមច្រើនដែរទេអ៊ុំ?

ខៈ អើរចិញ្ចឹមពេញតែភូមិដែរនឹងភូមិធំហោស

កៈ អូ៎!!បាទអ៊ុំបាទចឹង?

ខៈ សប្បាយហូបដែរនឹងនៅជំនាន់ណុងហាស

កៈ
ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំនឹងមានការផ្លាស់ប្តូរអីគេខ្លះដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាសអ៊ុំ?

ខៈ អត់មានការផ្លាស់ប្តូរអីសោះនឹងហាសឥឡូវនឹងខ្ញុំឈប់ហើយនឹង

កៈ អូ៎!!បាទចឹងហោសអ៊ុំ?

ខៈ កូនចៅគេចិញ្ចឹមហើយនឹងហាស

កៈ អូ៎!!បាទអ៊ុំបាទ ចុះអ៊ុំគិតថាល្បែងប្រជាប្រិយ៍អីដែរធ្លុំចូលចិត្តលេងកាលពីក្មេងហាសអ៊ុំ?

ខៈ អត់អត់មានសោះលេងនឹងកាលពីជំនាន់ទៅឃ្វាលគោ ឃ្វាលក្របីអីនឹង
យើងចេះតែលេងប៉ែង លេងអីនឹងមានតែប៉ុណ្ណឹងទេ

កៈ អ៊ុំលេងតែកូនប៉ែងទេណាអ៊ុំ?

ខៈ បាទនឹងហើយចឹង តែបើបៀរ អាប៉ោងអីនឹងមិនចេះតែម្តងនឹងហាស

កៈ ប៉ុន្តែដូចជាអ៊ុំលេងល្បែងដូចជាចោលឈូង បោះអង្គុញ លាក់កន្សែងអីចឹងហាស?

ខៈ នឹងហើយនឹង

កៈ នឹងអ៊ុំលេងមែនទេអ៊ុំ?

ខៈ នឹងលេងលេងម្តងម្កាលនឹងហាស លេងម្តងៗចូលលេងបោះអង្គុញអីចឹងទៅ

កៈ ប៉ុន្តែភាគច្រើននឹងអ៊ុំលេងនៅពេលណាដែរអ៊ុំ លេងនៅពេលដែរចូលឆ្នាំមែនទេអ៊ុំ?

ខៈ លេងនៅពេលចូលឆ្នាំ រឺក៏នៅពេលភ្ជុំអីចឹងទៅ

កៈ កាលលេងនឹងលេងនៅក្នុងភូមិ រឺលេងនៅវត្ត?

ខ៖ លេងនៅវត្តនឹងហាស

ក៖ អូ!!លេងនៅវត្តហោសអ៊ំ ចុះអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខ៖ អើរម្ហូបនឹងវាមិនទៀងទេមិនដឹងថាចង់ហូបអីទេ ទិញយកមកធ្វើទៅនឹង

ក៖ អូ!!បាទអ៊ុំបាទចឹង?

ខ៖ មានស្លម្ជូរ កកូរនឹង

ក៖ បាទអ៊ុំបាទ?

ខ៖ ម្ហូបខ្មែរយើងមានតែប៉ុណ្ណឹង ប្រហើរអី

ក៖ ប៉ុន្តែបើអោយអ៊ុំនឹកឃើញចូលចិត្តតែម្តងនឹងអ៊ុំអត់ប្រាកដទេណាអ៊ុំ?

ខ៖ អត់ប្រាកដទេ

ក៖ អូ!!បាទអ៊ុំចុះបើសិន?

ខ៖ ចិត្តចំណង់ចង់ហូបអីចឹងទៅទិញមកធ្វើហូបចឹងទៅ

ក៖ ចុះកាលពីក្មេងនឹងអ៊ុំចូលចិត្តច្រៀងដែរទេអ៊ុំ?

ខ៖ អត់ទេអត់ចូលចិត្តទេ

ក៖ ប៉ុន្តែអ៊ុំចូលចិត្តស្តាប់បទចំរៀងដែរទេអ៊ុំ?

ខ៖ ចូលចិត្តដែរតើ ច្រៀងបទពីសង្គមនឹងហាស

ក៖ លក្ខណះថាបទពីដើមនឹងណាអ៊ុំ?

ខ៖ នឹងហើយបទពីដើមនឹងហាសបទពីដើមនឹងពិរោះតែបទឥឡូវនឹងមិនចេះស្តាប់ទេ

ក៖ អត់ដឹងថាស្តាប់អីគេទេនឹង ចុះអ៊ុំចូលចិត្តស្តាប់យីកេ អាយៃអីទេអ៊ុំ?

ខ៖ នឹងហើយយីកេ អាយៃពីដើមនឹងមិនចឹង ល្ខោនអីនឹង

ក៖ បាទអ៊ុំបាទអ៊ុំ?

ខ៖ ចាពៃអីនឹងហាសនឹងហើយបទពីដើមនឹងហើយ

កៈ
ចុះអ៊ុំគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសាររបស់អ៊ុំនឹងមានចេះលេង៉បករណ៍ភ្លេងដែរទេអ៊ុំ?

ខៈ អ៎ូ!!អត់ចេះសោះតែម្តងនឹងហាស

កៈ អត់មានបងប្អូនសាច់ញ្ញាតិអីទេហោសអ៊ុំ?

ខៈ កូនរបស់ខ្ញុំអាបងនឹងវាពេទ្យ មួយទៀតនឹងទើបតែការនៅថៃ មួយទៀតរត់តុ តុ

កៈ អ៎ូ!!ចឹងហោសអ៊ុំបាទ?

ខៈ មួយទៀតនឹងអាពៅនឹងនៅធ្វើសក់អីអោយគេនឹងមិនទាន់ចេះបានការងារណា

កៈ អ៎ូ!!ចឹងហោសអ៊ុំ?

ខៈ
ប្រលងអាហារូបករណ៍បានសញ្ញាប័ត្រប៉ុន្តែរកការងារអត់ទាន់បានហាសចេះតែចាយសិនទៅ

កៈ អ៎ូ!!បាទអ៊ុំបាទ ចុះផ្ទះរបស់អ៊ុំនឹងមានលក្ខណះបែបណាដែរអ៊ុំ
តាំងពីក្មេងរហូតមកដល់ពេលនេះហាស?
ខៈ នៅសព្វថ្ងៃនឹងហោស

កៈ បាទអ៊ុំបាទនឹងហើយ?

ខៈ មានអីធម្មតានឹងហាស

កៈ អ៎ូ!!ផ្ទះឈើលើថ្មខាងក្រោមណាអ៊ុំ?

ខៈ នឹងហើយមានប្លង់រឹងធម្មតានឹងហាស

កៈ ប៉ុន្តែផ្ទះណុងដូចជាអ៊ុំមានចេះធ្វើផ្ទះដែរទេអ៊ុំ?

ខៈ ឯត់អត់ចេះធ្វើផ្ទះទេ

កៈ ប៉ុន្តែអ៊ុំបានជួលគេណាអ៊ុំ?

ខ៖  បាទខ្ញុំជួលគេតើនឹង

ក៖
ចុះអ៊ុំមានដឹងថាផ្ទះរបស់អ៊ុំដែរធ្វើនឹងគេមានប្រើឧបករណ៍អីគេដែរសំរាប់សាងសងទេអ៊ុំ?

ខ៖  ខាងសាងសនឹងមានតែគ្រឿងសំភារះរបស់វានឹងហាស មានម៉ាស៊ីនបុកគ្រឹសអីចឹងទៅ

ក៖  មានឈើ មានស៊ីម៉ង់អីចឹងទៅ?

ខ៖  មានឈើនឹងគេមានជាងឈើផ្សេងទៀតទៅនឹងហាស

ក៖  ស៊ីម៉ង់ជាងឥដ្ឋការ៉ូអីផ្សេងទៀតនឹង?

ខ៖  នឹងហើយចឹងគេធ្វើអាចាក់បេតុអីទៀតនឹងគេធ្វើហើយនឹង

ក៖  បាទអ៊ុំបាទចឹង?

ខ៖  ហើយបើឈើនឹងមានជាងឈើគេផ្សេងទៀតនឹងហាស

ក៖  ចុះអ៊ុំគិតថាជំនាញអីដែរអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំ?

ខ៖  អ៊ូ!!មានតែធ្វើម៉ូតូជួសជុលកង់អីនឹងហាស

ក៖  អ៊ូ!!បាទអ៊ុំបាទ?

ខ៖  បើខ្ញុំចិញ្ចឹមកូនបានសព្វថ្ងៃនឹងហាស

ក៖  ដោយសារតែជួសជុលម៉ូតូណាអ៊ុំណា?

ខ៖  នឹងហើយចឹង

ក៖  ចុះអ៊ុំគិតថាម្តាយឪពុករបស់អ៊ុំគាត់ធ្លាប់បង្រៀនពីជំនាញអីទៅអ៊ុំដែរទេអ៊ុំ?

ខ៖  អត់ទេអត់ដែរបានបង្រៀនអីផងនឹង

ក៖  កូរស្ករ វេញវល្លិ៍ ធ្វើផ្តៅអីក៏អត់ដែរដែលណាអ៊ុំ?

ខ៖  អត់ដែរទេនឹងហាស

កៈ
ចុះអ៊ុំអាចប្រាប់ខ្ញុំបានទេពីពេលដែរដំបូងពិបាកហាសពីក្មេងនឹងអ៊ុំលំបាកអីគេខ្លះដែរទៅអ៊ុំ?

ខៈ ពីក្មេងនឹងមានការលំបាកនឹងចង់និយាយថាយើងមានការខ្វះខាតនឹងហាស

កៈ ហើយនៅជំនាន់ណុងជាជំនាន់សង្គ្រាមនឹងហោសអ៊ុំ?

ខៈ ណុងហើយជំនាន់លុនណុល ជំនាន់យាគកុងគ្មានបានទៅរកស៊ីអីទេ

កៈ ចុះពេលជំនាន់លុនណុលជំនាន់យាគកុងចឹងទៅគេអោយអ៊ុំធ្វើអីគេដែរអ៊ុំ?

ខៈ អើរកាលណុងធ្វើឆ្លប់អីដែរនឹងហាស ធ្វើឆ្លប់ភូមិនឹងហាស

កៈ ប៉ុន្តែគេមិនមែនអោយធ្វើជាទាហ៊ានអីណាហីអ៊ុំ?

ខៈ អត់មានទេយើងអត់ទៅនឹងហាស

កៈ អូ៎!!បាទអ៊ុំបាទនឹង?

ខៈ នឹងហើយវាចឹង

កៈ ចុះជំនាន់ពលពតនឹងអ៊ុំមានការលំបាកអីគេដែរទៅអ៊ុំ?

ខៈ នៅពេលពលពតនឹងខ្ញុំរត់ទៅនៅព្រំដែនអស់ហើយនឹង

កៈ អូ៎!!ចឹងអ៊ុំទៅនៅព្រំដែនវៀតណាមហើយនឹងអ៊ុំ?

ខៈ នឹងហើយទៅនៅព្រំដែនវៀតណាមហើយនឹង

កៈ ចឹងអ៊ុំអត់មានការលំបាកអីទេហោសអ៊ុំ?

ខៈ កាលណុងក៏ពិបាកដែរគ្មានពេលរកស៊ីទេ មិនដូចយើងពីឥឡូវនឹងទេ
ពិបាករកស៊ីយើងអត់ចេះភាសា

កៈ យើងគ្រាន់តែពិបាករកស៊ីប៉ុន្តែយើងមិនបានមកពិបាកវេទនាដូចគេនៅនេះហាសហីអ៊ុំ?

ខៈ អត់ទេមានតែបងមួយនៅនឹងអាពតគេយកទៅ

កៈ សំលាប់ចោលបាត់ទៅ?

ខ៖ យកទៅសំលាប់ចោលនឹងហើយ

ក៖ ក្រៅពីនឹងគ្រួសាររបស់អ៊ុំនឹងផ្លាស់ទៅនឹងទាំងអស់នឹង?

ខ៖ នឹងហើយចឹង

ក៖ ចុះកាលពីជំនាន់ណុងអ៊ុំទៅរកស៊ីអីគេដែរនៅព្រំដែននឹងហាសអ៊ុំ?

ខ៖ ទៅណុងចុះកាលណុងវានៅព្រៃដែរទៅកាប់អូស
កាប់អីដែរនឹងទៅលក់អោយគេចឹងទៅ

ក៖ បាទអ៊ុំ ខ្ញុំសុំសួរមួយអ៊ុំ ដូចជាអ៊ុំមានដឹងថាមានហេតុការណ៍នឹងកើតឡើងពីមុនរឺមួយក៏អ៊ុំអត់មានដឹងទេបានជាគ្រួសាររបស់អ៊ុំផ្លាស់ទៅណុងតែម្តងនឹងហាសអ៊ុំ?

ខ៖ ដឹងដែរតើនឹង

ក៖ ចឹងដឹងហើយបានជាអ៊ុំផ្លាស់ទៅណុងតែម្តងនឹងហោសអ៊ុំ?

ខ៖ ដឹងក្នុងជំនាន់ឆ្នាំ1976នឹង

ក៖ ចឹងមានន័យថាអ៊ុំបានទាន់បានមួយឆ្នាំហោសអ៊ុំ នៅនឹងបានមួយឆ្នាំហោសអ៊ុំ?

ខ៖ បាទនឹងហើយបាន

ក៖ ចុះកាលពីឆ្នាំ1975ដំបូងនឹងពលពតចូលដំបូងនឹងមកអ៊ុំនៅណាដែរទៅអ៊ុំ?

ខ៖ ពេលដែរពលពតនឹងចូលមកនឹងនៅស្រុកប៉ុន្តែចុងឆ្នាំបានជាខ្ញុំទៅនឹងហាស

ក៖ អូ!!ប៉ុន្តែពេលណុងគេមានប្រើអោយអ៊ុំធ្វើអីគេទេអ៊ុំ?

ខ៖ អត់ទេអត់មានទេ

ក៖ គ្រួសាររបស់អ៊ុំនឹងក៏គ្មានបញ្ហាអីគេដែរ?

ខ៖ អត់ទេនឹងស៊ីសងលើយើងនៅស្រុកនឹងប្រធានភូមិអីគេដឹងហាស

ក៖ បាទអ៊ុំបាទ ប៉ុន្តែពេលណុងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ កាលណុងអាយុជាប់40ឆ្នាំហើយយ៉ាង

កៈ អ៊ូ!!អ៊ុំមានអាយុច្រើនដែរហើយហោសអ៊ុំមានកូនចៅហើយនឹងអ៊ុំ?

ខៈ អើរមានកូនចៅពីរហើយនឹង

កៈ ប៉ុន្តែទាល់តែដាច់ពលពតនឹងបានអ៊ុំរត់មកវិញរឺយ៉ាងម៉េចដែរអ៊ុំ?

ខៈ មកពេលជំនាន់រដ្ឋកម្ពុជានឹងហាស

កៈ អ៊ូ!!បាទអ៊ុំ ចុះពេលដែរអ៊ុំមកនឹងពេលដាច់ពលពតថ្មីៗនឹងអ៊ុំមកធ្វើអីគេដែរអ៊ុំ ពេលណុងមានការលំបាកអីគេផ្សេងទៀតទេអ៊ុំ?

ខៈ រឿងរកស៊ីនឹងយើងចេះតែលំបាកហើយនឹងចុះយើងមានដើមណារកស៊ី

កៈ បាទត្រូវហើយនឹង?

ខៈ នឹងហើយយើងចេះតែអង្គុយប៉ះកង់ប៉ះអីចឹងទៅ

កៈ អ៊ូ!!បាទអ៊ុំបាទចឹង?

ខៈ ពេលមុនដំបូងខ្ញុំមកនឹងខ្ញុំរត់កង់ឌុបទេនឹងហាស

កៈ បាទអ៊ុំបាទចឹង?

ខៈ រត់កង់ឌុបនឹងទិញអង្ករទៅគេអោយតអង្ករអីចឹងទៅណាស់ទុកហូបទៅ

កៈ ចុះអ៊ុំគិតថាកាលលំបាកឧបសគ្គនឹងអ៊ុំពុះពារដោយរបៀបណាដែរអ៊ុំ?

ខៈ អានឹងវាអើរអានឹងវាតាមកាលៈទេសៈហាស

កៈ បាទអ៊ុំបាទចឹង?

ខៈ នឹងហើយចឹងយើងធ្វើទៅបានទៅយើងធ្វើទៅមិនបានទេអត់ទៅនឹង

កៈ
បាទអ៊ុំចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់អ៊ុំដែរ?

ខៈ មានតែពេលនឹងទេគ្មានពេលណាទៀតទេ

កៈ អ៊ូ!!បាទអ៊ុំបាទ ចុះពេលដែរអ៊ុំការនឹងអ៊ុំគិតថាអ៊ុំសប្បាយទេអ៊ុំ?

ខ៖
ការហោសការនៅជំនាន់នេះជំនាន់លុនណុលនឹងពិបាកចង់ស្លាប់ហើយនឹងលែងតែភ័យនឹង

ក៖ អ៊ុំបានការនៅឆ្នាំណាដែរអ៊ុំ?

ខ៖ នៅក្នុងឆ្នាំ1979នឹង

ក៖ នៅឆ្នាំ1979នឹងអូដាច់ពលពតហើយនឹងចឹងហោស?

ខ៖ នឹងហើយដាច់ពលពតហើយនឹងហាស

ក៖ ប៉ុន្តែដាច់ភ្លាមៗៗចឹងក៏មិនសូវសប្បាយដែរណអ៊ុំ?

ខ៖ អត់ទេនៅខ្លាចនៅឡើយនឹងកាលណុងក្រាលកន្ទេលនៅក្រោមហូបតើនឹង

ក៖ អូ៎!!ប៉ុន្តែអ៊ុំការនឹងអ៊ុំការនៅណាដែរអ៊ុំ?

ខ៖ នៅស្រុកនឹងនៅស្រុកតើនឹង

ក៖ នៅព្រៃវែងហោសអ៊ុំ ប៉ុន្តែដូចជាកាលពីការកូនអីនឹងអ៊ុំគិតថាសប្បាយទេអ៊ុំការណុង?

ខ៖ អូ៎!!ការកូននឹងសប្បាយតើនឹង

ក៖ អូ៎!!ដោយសារតែពេលណុងអស់អីហើយណអ៊ុំ?

ខ៖ បាទនឹងការកូននឹងអាធិកអាធាប់ហើយនឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទចឹង?

ខ៖ ការស៊ីនៅហាងនៅអីចឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទល្អ ចុះអ៊ុំមានធ្លាប់គិតថាកាលពីក្មេងអ៊ុំ
ធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹងអ៊ុំចង់ធ្វើអីដែរទេអ៊ុំ?

ខ៖
កាលពីដើមនឹងចិត្តចង់រៀនអោយវាចេះប៉ុន្តែវាមិនចេះអស់ចប់ចុងចប់ដើមចឹងវាគ្មានការងារធ្វើទេ

កៈ ប៉ុន្តែអ៊ុំធ្លាប់គិតថាកាលពី?

ខៈ ខ្ញុំចង់ហើយនឹងហើយនខ្ញុំចង់ធ្វើចឹង

កៈ កាលពីក្មេងអ៊ុំធ្លាប់គិតថាអ៊ុំចង់ធ្វើពេទ្យ ធ្វើជាទាហ៊ាន ធ្វើជាប៉ូលីសអីទេ?

ខៈ ធ្វើជាទាហ៊ាននឹងអត់ចង់ទេចង់ធ្វើជារាជការនឹងហាស

កៈ ចង់ធ្វើការងារនៅក្នុងរាជការណាអ៊ុំ?

ខៈ នឹងហើយចឹង

កៈ
អូ្ន!!បាទបើសិនជាចង់អោយអ៊ុំផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗនឹងអ៊ុំចង់ផ្តែផ្តាំអីទៅពួកគាត់ដែរអ៊ុំ?

ខៈ អានឹងអោយវាខំប្រឹងប្រែងរៀនទៅនឹងការងារ
ដូចជាពេទ្យអីនឹងវារស់ស្រួលរបស់វាហើយនឹង

កៈ អូ្ន!!បាទចឹងអ៊ុំចង់អោយពួកគាត់រៀនពេទ្យអីដើម្បីអោយពួកគាត់ធ្វើពេទ្យអីណាអ៊ុំ?

ខៈ នឹងហើយចឹង

កៈ ចុះអ៊ុំមានអីដែរចង់ផ្តែផ្តាំអីទៅពួកគាត់ផ្សេងទៀតទេអ៊ុំ?

ខៈ អានឹងចុងក្រោយហើយនឹងហាសចង់ផ្តែផ្តាំតែប៉ុណ្ណឹង
អោយខំប្រឹងប្រែងយកចំនេះវិជ្ជាទៅអានឹង យើងចង់រកស៊ីខាងផ្នែកអីអោយមាន

កៈ យើងរៀនផ្នែកអីចឹង?

ខៈ ដូចថាផ្នែកទីផ្សារអីចឹង

កៈ
យើងរៀនផ្នែកអីយើងទៅធ្វើការងារផ្នែកមួយនឹងតាមអ្វីចំណង់ចំណូលចិត្តរបស់យើងទៅណាអ៊ុំ?

ខៈ អើរអានឹងចឹងអាកូនមួយនឹងវាការងារទីផ្សាររបស់វាដែរនឹង

ក៖ បាទអ៊ុំបើសិនជាចង់អោយពួកគាត់ជៀសវៀងហាសកូនចៅរបស់អ៊ុំជៀសវៀងហាស តើចង់អោយពួកគាត់ជៀសវៀងអីគេដែរអ៊ុំ?

ខ៖ ជៀសវៀងអាជៀសវៀងអោយយើងខំប្រឹងប្រែងទៅកុំអោយវា អោយមានការងារអីប្លែកៗៗចឹងហាស

ក៖ ចុះបើទាក់ទងនឹងគ្រឿងញៀនអីចឹង?

ខ៖ នឹងហើយប្លែកៗៗនឹងហើយចឹងកុំអោយមាន

ក៖ បាទអ៊ុំបាទចឹង?

ខ៖ យើងខំប្រឹងរកស៊ីទៅនឹង

ក៖ បាទអ៊ុំបាទចឹង?

ខ៖ ពីព្រោះប្រទេសយើងនឹងសំបូរសប្បាយហើយនឹងម៉េចទៀត ហើយមានលុយមានកាក់ចាយហើយ មានច្រើនទៅអានឹងកាន់តែសប្បាយទៀតហើយនឹងហាស

ក៖ បាទអ៊ុំបាទអ៊ុំមានអីទៀតទេ?

ខ៖ មានអីត្រូវខ្លាចសង្គ្រាមអីទៀត

ក៖ ប៉ុន្តែមានអីចង់ផ្តែផ្តាំផ្សេងទៀតទេអ៊ុំ?

ខ៖ អត់មានទេអស់ហើយនឹងហាស

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំបានពិភាក្សាជាមួយខ្ញុំដែរទាក់ទងពីប្រវត្តិរបស់អ៊ុំ នឹងហាសអ៊ុំបាទចឹងអរគុណច្រើនអ៊ុំ៕៕៕